ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ៣៤៨

ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៩ **នាមនាមប្រជារាស្ត្រខ្មែរ**

សាលដីកា **តុលាការកំពូល**

លេខៈ ២២១

ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០០២ បានបើកសវនាការជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០០២

ដោយមានសមាសសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឃឹម | ប៊ុណ្ណ | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២-លោក | វឿល | មួន | ជាចៅក្រម |
| ៣-លោក | ស៊ិន | ឌីម | ជាចៅក្រម |
| ៤-លោក | ជីវ | កេង | ជាចៅក្រម |
| ៥-លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៦-លោក | ប្រាក់ | គីមសាន | ជាចៅក្រម |
| ៧-លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម-របាយការណ៍ |
| ៨-លោក | យស់ | សូខឿន | ជាចៅក្រម |
| ៩-លោក | គង់ | ភីរុន | ជាចៅក្រម |

ក្រឡាបញ្ជី

| | | | |
|---|---|---|---|
| កញ្ញា | ហុក | សុខធុល | |

តំណាងមហាអយ្យការ

| | | | |
|---|---|---|---|
| លោក | ឈួន | ចាន់ថា | ជាអគ្គព្រះរាជអាជ្ញា |

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៦៥៦ ចុះថ្ងៃទី០៩-៩-៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ០៩ ចុះថ្ងៃទី ០៧-០៤-៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ **តាំង** **មួរ** អាយុ ៦២ឆ្នាំ មុខរបរ នៅផ្ទះ ទីលំនៅផ្ទះលេខ ៧៧អឺសូន្យ ផ្លូវលេខ ១៩ ក្រុម ៤៦ សង្កាត់ផ្សារកណ្តាល ២ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ **លីម** **អ៊ី** ភេទស្រី អាយុ៤៣ ឆ្នាំ មុខរបរ នៅផ្ទះ ទីលំនៅផ្ទះ

លេខ ៧៧អឺសូឡុ ផ្លូវលេខ ១៩ ក្រុម ៤៦ សង្កាត់ផ្សារកណ្ដាល ២ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

**កម្មវត្ថុបណ្ដឹង** :បដិសេធប័ណ្ណគ្រួសារលេខ៩៥សៀវភៅលេខ៧៧ ចុះថ្ងៃទី១៤-៨-៩២។

បានឃើញបណ្ដឹងសាទុក្ខលើកទី២ លេខ ៣៦១ ចុះថ្ងៃទី១៣-៩-៩៩ របស់អ្នកស្រី តាំង បូរ ប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ ៦៥៦ ចុះថ្ងៃទី ០៩-៩-៩៩ របស់សាលាឧទ្ធរណ៍លើសេចក្ដីសំរេចទាំងមូល ។

បានឃើញ សំណុំរឿងលេខ ៣៤៨ ចុះថ្ងៃទី ១០-១១-៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ២៥-៨-៩៧ របស់អ្នកស្រីតាំង បូរ ប្ដឹងសុំបដិសេធ ប័ណ្ណសំគាល់គ្រួសារ លេខ ៩៥ សៀវភៅលេខ ៧៧ ចុះថ្ងៃទី ១៤-៨-៩២ និង សុំឱ្យអ្នកស្រីលឹម រ៉ៃ ចុះចេញពីផ្ទះដោយហេតុថា លោក គង់ អុល ប្ដីរបស់អ្នកស្រី លឹម រ៉ៃ បានលួចធ្វើប័ណ្ណគ្រួសារថ្មី ដោយមិនមានការយល់ព្រមពីអ្នកស្រី ផ្ទះនេះជាផ្ទះអ្នកស្រីប្ដូរគ្នាជាមួយឈ្មោះ គីម អ៊ិក កាលពីឆ្នាំ១៩៨០ អ្នកស្រីបានប្រគល់ផ្ទះរបស់អ្នកស្រី នៅផ្សារអូរឫស្សី អោយទៅឈ្មោះ គីម អ៊ិក ។ នៅឆ្នាំ ១៩៨៧ កូនអ្នកស្រីលឹម រ៉ៃ បានលួចលុយរបស់អ្នកស្រី ពេលឆែកឆេរ ទើបអ្នកស្រីឃើញប័ណ្ណគ្រួសារថ្មី ប្ដឹងសុំបដិសេធ ។

បានឃើញសាលក្រមលេខ ១២៩ "ក" ចុះថ្ងៃទី ២២-១០-៩៧ របស់តុលាការក្រុងភ្នំពេញ ដែលមានសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ២៥-៨-៩៧ របស់ដើមចោទឈ្មោះ តាំង បូរមានលក្ខណៈត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធប័ណ្ណសំគាល់គ្រួសារលេខ៩៥សៀវភៅលេខ៧៧ ចុះថ្ងៃទី១៤-៨-៩២ ចោល គិតចាប់ពីសាលក្រមចូលជាស្ថាពរ ។

៣-បង្គាប់ឱ្យដើមចោទ ឈ្មោះ តាំង បូរ ប្រគល់ប្រាក់ ៣.០០០ដុល្លាឱ្យទៅឈ្មោះ លឹម រ៉ៃ ចាប់តាំងពីសាលក្រមចូល ជាស្ថាពរ ។

៤-បង្គាប់ឱ្យឈ្មោះ លឹម រ៉ៃ ចុះចេញពីផ្ទះលេខ ៧៧អឺសូឡុ ផ្លូវលេខ១៩ក្រុម១០ សង្កាត់ផ្សារកណ្ដាល ២ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ចាប់ពីសាលក្រមចូលជាស្ថាពរ ។

៥-បង្គាប់ឱ្យឈ្មោះ លឹម រ៉ៃ បង់ប្រាក់ប្រដាប់ក្ដីចំនួន ៧.០០០រៀល គឺពន្ធចុះបញ្ជីនិងពន្ធហ្នឹង ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់សាក្សី ២.០០០រៀល អ្នកប្រគល់ដីកាកោះ ៣.០០០រៀល សរុប ៧.០០០រៀល ប្រាក់នេះត្រូវបានកាត់យកពីដើមចោទបានបង់ទុករួចហើយ ។ កាលបើហួសឧទ្ធរណ៍ បង្គាប់ឱ្យឈ្មោះ លឹម រ៉ៃ សងប្រាក់ ៧.០០០រៀល ឱ្យទៅ

ដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រ ១% លើតំលៃផ្ទះ ប្រាក់នេះត្រូវ បង់ចូលថវិការដ្ឋចំនួន៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៦-សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខគូភាគី សំរេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣-១២-៩៧ របស់ឈ្មោះ លឹម រ៉ៃ មិនសុខចិត្តនឹងសាលក្រមនេះទាំងមូល ។

បានឃើញសាលដីកាលេខ ២៥៩ ចុះថ្ងៃទី ២៨-៥-៩៨ របស់សាលាឧទ្ធរណ៍ ដែលសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍របស់នាងលឹម រ៉ៃ ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ១២៩"ក" ចុះថ្ងៃទី ២២-១០-៩៧ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣-សំរេចថាផ្ទះកើតហេតុលេខ ៧៧អឺសូន្យ និង អឺ១ ស្ថិតនៅផ្លូវលេខ ១៩ ក្រុម ១០ សង្កាត់ផ្សារកណ្តាល ២ ខ័ណ្ឌដូនពេញ ត្រូវចែកជាពីរ ស្មើគ្នា គឺ ភាគីដើមចោទឈ្មោះ តាំង បូរ ត្រូវបានពាក់កណ្តាល និង ភាគីចុងចម្លើយឈ្មោះ លឹម រ៉ៃ ត្រូវបានពាក់កណ្តាល ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ ដើមបណ្តឹងឧទ្ធរណ៍ បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹង ២.៩៥០ រៀលរង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀលចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល ។

កាលបើហួសកំណត់ប្តឹងសាទុក្ខ បង្គាប់ឱ្យគូភាគីរួមគ្នា បង់ពន្ធសមាមាត្រ១% លើតំលៃផ្ទះ ទាស់ ប្រាក់ពន្ធនេះ ៨០% ត្រូវបានជាប្រយោជន៍ថវិកាជាតិ និង ២០% ត្រូវបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជា សាធារណៈចំពោះមុខគូភាគី សំរេចបើកផ្លូវ ប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ ២៣៥ ចុះថ្ងៃទី ១៧-៦-៩៨ របស់ឈ្មោះតាំង បូរ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីកាលេខ ១១ ចុះថ្ងៃទី ១៤-០១-៩៩ របស់តុលាការកំពូល ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ ២៣៥ ចុះថ្ងៃទី១៧-៦-៩៨ របស់អ្នកស្រីតាំង បូរ ទុកជាត្រឹមត្រូវ តាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ ២៥៩ ចុះថ្ងៃទី ២៥-៥-៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២១៩ ចុះថ្ងៃទី១១-៨-៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលអ្នកស្រី តាំង បូរ បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតំរូវឱ្យអ្នកស្រីលឹម រ៉ៃ សងប្រាក់ចំនួន ១៩.០០០រៀល នេះទៅឱ្យអ្នកស្រីតាំង បូរវិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី ១៤ ខែមករា ឆ្នាំ ១៩៩៩ ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ៦៥៦ ចុះថ្ងៃទី ០៩-៩-៩៩ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះរឿងក្តីនេះឡើងវិញ តាមអំណាចសាលដីការបស់តុលាការកំពូលលេខ ១១ ចុះថ្ងៃទី ១៤-០១-៩៩ ។

២-បង្គាប់អោយឈ្មោះ លឹម រ៉ៃ ( មានលោក ឌួង សារ៉ាត ជាតំណាង ) ប្រគល់ប្រាក់ចំនួន១០.០០០ដុល្លាអាមេរិចអោយទៅឈ្មោះតាំង បូរ ចាប់ពីថ្ងៃដែលសាលដីកានេះចូលជាស្ថាពរ ។

៣-បង្គាប់ឱ្យឈ្មោះតាំង បូរ ចុះចេញពីផ្ទះទំនាស់លេខ ៧៧ អឺសូឡ្យ អឺ១ ផ្លូវលេខ ១៩ សង្កាត់ផ្សារកណ្តាល ២ ខ័ណ្ឌដូនពេញ ចាប់ពីថ្ងៃដែលសាលដីកានេះ មានអនុភាពអនុវត្ត។

- ប្រគល់ផ្ទះទំនាស់លេខ៧៧ អឺសូឡ្យ អឺ១ខាងលើឱ្យទៅដើមបណ្តឹងឧទ្ធរណ៍ឈ្មោះ លឹម រ៉ៃ ធ្វើជាកម្មសិទ្ធិតទៅ ។

៤-សាលដីកានេះជំនុំជំរះនៅថ្ងៃទី ០២-៩-៩៩ និងប្រកាសជា សាធារណៈចំពោះមុខគូក្តី នៅថ្ងៃទី ៩-៩-៩៩ បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ ៣៦១ ចុះថ្ងៃទី ១៣-៩-៩៩ របស់អ្នកស្រីតាំង បូរ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីការបៀបលេខ ១៤៩ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០០១ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ចាត់របៀប ឱ្យធ្វើការស៊ើបអង្កេតបន្ថែម និងចុះពិនិត្យដល់ទីតាំងផ្ទះទំនាស់ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ៦៥៦ ចុះថ្ងៃទី ៩-៩-៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទំរង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និងសំរេច ។

បានស្តាប់ចំលើយរបស់ឈ្មោះ តាំង បូរ នៅពេលជំនុំជំរះថា : ខ្ញុំមានសាក្សី ដែលខ្ញុំបានទិញផ្ទះ នេះពីលោក គឺលោកបានលក់អោយមកខ្ញុំទាំងប្តីប្រពន្ធ គ្មានឃើញកូនអ្វីទេ ស្រាប់តែនាង លឹម រ៉ៃ មកថា ផ្ទះនេះ ជារបស់គេ តាមពិតខ្ញុំទិញ លក់តាម លក់ត្រឹមត្រូវ ។ សព្វថ្ងៃនេះ នាង លឹម រ៉ៃ មានកេរ្តិ៍ពីរ ហើយបើនាងថា ជាន់ទី១ នាងបានទិញ ហេតុអ្វីក៏នាង មិនឡើងទៅរស់នៅទៅ ម៉េចមកនៅច្រប្លុកច្របល់ជាមួយខ្ញុំអញ្ចឹង ហេតុអីក៏នាង មិនធ្វើប័ណ្ណដាក់ជាន់ទី១ជងទៅ ។ ចង្ក្រានបាយ ខ្ញុំកាន់កាប់ បន្ទប់ទឹកប្រើប្រាស់រួម ។ លឹម រ៉ៃ បានមកស្នាក់នៅ ឆ្នាំ១៩៨២ ដោយប្តីនាងបានមកសុំខ្ញុំស្នាក់នៅ ហើយប្តីងគ្នានៅឆ្នាំ ១៩៩៧ ដោយសារខ្ញុំបាត់លុយ សុំឆែកឆេរទៅ ទើបឃើញ នាងលឹម រ៉ៃ លួចធ្វើប័ណ្ណនេះទៅ ។ នាងលឹម រ៉ៃ ឃើញមករកស៊ីនៅផ្ទះនេះ តែថ្ងៃទេ ពេលយប់ មិនដឹងជានៅទីណាទេ មានតែកូនប្រុសទេ ដែលដេកនៅផ្ទះនេះ ។ កាលដែលខ្ញុំមិនបាននៅផ្ទះជាប់លាប់ ព្រោះខ្ញុំត្រូវចេញទៅរកស៊ីនៅកំពង់សោមជាធម្មតា ។

ខ្ញុំសូមឱ្យតុលាការជួយរកយុត្តិធមិឱ្យនាងខ្ញុំផង ។

បានស្តាប់ចំលើយរបស់ឈ្មោះលឹម រ៉ៃ នៅពេលជំនុំជំរះថា ខ្ញុំមិនទទួលស្គាល់រាល់អ្វីដែលគាត់បាននិយាយទាំងប៉ុន្មាននេះទេ ខ្ញុំមិនបាននៅជាមួយគាត់ទេ គឺខ្ញុំចូលទៅនៅផ្ទះនេះ តាំងពីឆ្នាំ ១៩៨២ ប្តីខ្ញុំជាអ្នកទិញផ្ទះនេះ គាត់ទើបមកនៅឆ្នាំ ១៩៩៧ ។ នៅជាន់ទី ១ អី១ ខ្ញុំមិនបាននៅទេ ព្រោះវាលិចទឹកពេលភ្លៀង ខ្ញុំគ្រាន់តែឡើងទៅបោសសំអាត នៅខាងលើនេះ គ្មានអ្នកណានៅទេ ។ គាត់ថាខ្ញុំមិនបានស្នាក់នៅពេលយប់ ព្រោះខ្ញុំត្រូវទៅស៊ីឈ្នួល លាងចាន កែវ អោយគេ ។

ខ្ញុំសូមអោយតុលាការជួយរកយុត្តិធម៌ អោយនាងខ្ញុំផង ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចំលើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សា ត្រឹមត្រូវ តាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៣៦១ ចុះថ្ងៃទី ១៣-៩-៩៩ របស់ឈ្មោះ តាំង បូរ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្ដី និងមាត្រា ២២៦ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ សំរេចប្រគល់ផ្ទះលេខ ៧៧អឺសូន្យ និង ៧៧អឺ១ ទាំងមូលឱ្យទៅអ្នកស្រី លឹម រ៉ៃ តែម្នាក់ឯង និងឱ្យលឹម រ៉ៃ ចេញប្រាក់ចំនួន ១ម៉ឺនដុល្លា អោយទៅអ្នកស្រីតាំង បូរ ទោះជាការភ័ន្ដច្រឡំ ពីព្រោះពុំមានភស្ដុតាងណាមួយថា អ្នកស្រី លឹម រ៉ៃ បានទិញ និងស្នាក់នៅ ផ្ទះនេះតែម្នាក់ឯងឡើយ ។

-យល់ឃើញថា គូភាគីនៃរឿងក្ដីនេះនៅតែអះអាងរៀង១ខ្លួនថា ខ្លួនបានទិញផ្ទះលេខ ៧៧ ផ្លូវលេខ ១៩ ក្រុម៤៦ សង្កាត់ផ្សារកណ្ដាល២ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ប៉ុន្ដែពុំមានភស្ដុតាងច្បាស់លាស់ណាមួយ ដែលអាចឱ្យតុលាការជឿបានឡើយប៉ុន្ដែគូភាគីបានរស់នៅរួមគ្នាលើផ្ទះទំនាស់នេះតាំងពីឆ្នាំ ១៩៨២ មកដែលមានសិទ្ធិលើផ្ទះនេះតាមទីកន្លែង ដែលខ្លួនបានរស់នៅ និងកាន់កាប់ជាក់ស្ដែង ។

-យល់ឃើញថា តាមការចុះពិនិត្យជាក់ស្ដែងដល់ទីកន្លែងកើតហេតុក៏ដូចចម្លើយរបស់អ្នកស្រី លឹម រ៉ៃ នាពេលសវនាការនោះដែរ ផ្ទះលេខ ៧៧ អឺ១ និងឡៅតឿរនៅជាន់ ៧៧ អឺសូន្យ អ្នកស្រី តាំង បូរ ជាអ្នកកាន់កាប់ផ្ដាច់មុខតែម្នាក់ឯង ហើយអ្នកស្រី លឹម រ៉ៃ ក៏ពុំដែលទៅស្នាក់នៅដែរ ដូច្នេះការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ផ្ទះលេខ ៧៧ អឺ១នេះ ទៅឱ្យអ្នកស្រី លឹម រ៉ៃ ក៏ជាការភ័ន្ដច្រឡំដែរ ។

-យល់ឃើញថា ក្នុងការរស់នៅជាក់ស្ដែង គូភាគីបានរស់នៅច្របូកច្របល់គ្នា នៅផ្ទះលេខ ៧៧អឺសូន្យ ដែលតុលាការគប្បីពិចារណាបែងចែកតាមស្ថានភាព ដាច់ដោយឡែកនិងតាមស្ថានភាពសំរាប់ សេវភាពរួម ។

- យល់ឃើញថា នៅផ្ទះលេខ ៧៧អឺសូន្យ អ្នកស្រីលឹម រ៉ៃ បានកាន់កាប់និងរស់នៅ ក្នុងបន្ទប់មួយ និងមានក្តារជឿមួយខាងមុខ ហើយអ្នកស្រីតាំង បូរ បានរស់នៅក្នុងបន្ទប់មួយ និងមានដាក់ក្តាជឿនៅពីមុខដែរ ដែលតុលាការគប្បីបែងចែកផ្នែកនេះ ដាច់ដោយឡែកពីគ្នា ឯទីតាំងក្រៅពីនេះគប្បីរក្សាទុក សម្រាប់ប្រើប្រាស់រួម ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៦៥៦ ចុះថ្ងៃទី ៩-៩-៩៩ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ មានការខុសឆ្គង ទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៣៦១ ចុះថ្ងៃទី ១៣-៩-៩៩ របស់អ្នកស្រី តាំង បូរ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណី លេខ ៦៥៦ ចុះថ្ងៃទី ០៩-០៩-៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-សំរេចបែងចែកផ្ទះលេខ ៧៧អឺសូន្យ តាមគំនូសប្លង់ចុះថ្ងៃទី ១៨-០១-០២ របស់ចៅក្រមតុលាការកំពូលដូចខាងក្រោម :

ក-ប្រគល់បន្ទប់ និងទីតាំងដែលតាងដោយលេខ I និងលេខ II ឱ្យអ្នកស្រីតាំង បូរ ។

ខ-ប្រគល់បន្ទប់ និងទីតាំងលេខ III និង IV ឱ្យអ្នកស្រីលឹម រ៉ៃ ។

គ-បន្ទប់ទឹក ចង្ក្រានបាយ និងទីតាំងក្រៅពីចំណុចលេខ I. II.III. និង IV ទុកជាសេវភាពរួម ។

៤-ប្រគលឡៅតឿនៃផ្ទះលេខ ៧៧អឺសូន្យ និងផ្ទះលេខ ៧៧ អឺ១ អោយអ្នកស្រីតាំង បូរ កាន់កាប់ ប្រើប្រាស់ ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលអ្នកស្រីតាំង បូរ បានបង់រួចហើយ គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹង ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

- ចំណោយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុបចំនួន ១៩.០០០រៀល ហើយតំរូវឱ្យអ្នកស្រី លឹម រ៉ៃ សងប្រាក់ចំនួន ១៩.០០០រៀល នេះទៅអ្នកស្រីតាំង បូរ វិញ ។

៦- សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០០២ ។